**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

# <u>កិច្ចព្រមព្រៀង</u>

## ស្តីអំពី
## ការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត
## រវាង
## ក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក
## និង
## សហជីពនិងតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ឌីន លីង

នៅថ្ងៃទី២៦ខែតុលាឆ្នាំ២០២៣វេលាម៉ោង១៥និង០០នាទីនៅការិយាល័យក្រុមហ៊ុនឌីនលីងហ្គាម៉ិនឯ.ក មានបើកកិច្ចប្រជុំស្តីពីការដាក់ព្យួរកិច្ចសន្យាការងាររបស់កម្មករនៃក្រុមហ៊ុនឌីនលីងហ្គាម៉ិន ឯ.កខាងមុខនេះ៖

**សមាភាពចូលរួមមាន៖**

-តំណាងក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក
-តំណាងសហជីពនិងតំណាងកម្មករ នៃក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក

ជាកិច្ចចាប់ផ្តើមលោកនាយកក្រុមហ៊ុនបានថ្លែងអំណរអរគុណដល់សមាជិកទាំងអស់ដែលមកចូលរួមប្រជុំ។ បន្ទាប់មកតំណាងក្រុមហ៊ុនបានលើកឡើងថា៖ ដោយសារតែសេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះក្រុមហ៊ុនឌីនលីងបានប្រឈមមុខនឹងគ្មានតម្រូវការទីផ្សាររបស់អ្នកប្រើប្រាស់ នឹងគ្មានការបញ្ជាទិញ ទើបក្រុមហ៊ុនសំរេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។ដែលមានកម្មករព្យួរសរុប៖ ៦៤នាក់ (ស្រី៦៤ នាក់ )

**ក្រោយពីបានពិភាក្សាគ្នាយ៉ាង ល្អិតល្អន់រួចមកភាគីទាំងអស់បានឯកភាពតាមកាលវិភាគនៃការព្យួរកិច្ចសន្យាការងារនិងប្រាក់ឧបត្ថម្ភដូចខាងក្រោម៖**

១-ក្រុមហ៊ុនឌីនលីងនឹងព្យួរកិច្ចសន្យាការងារ គឺគិតពីថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០២៣ ។

២-ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភចំនួន៣០ដុល្លា(សាមសិបដុល្លារអាមេរិក)សំរាប់ការព្យួរកិច្ចសន្យាការងារក្នុងខែវិច្ឆិកាឆ្នាំ២០២៣នេះនៅថ្ងៃទី៣១ខែតុលាឆ្នាំ២០២៣អោយបានមុនថ្ងៃព្យួរកិច្ចសន្យាការងារ។

ភាគីទាំងអស់ បានអានខ្លឹមសារ និង យល់ពីអត្ថន័យនៃកិច្ចព្រមព្រៀងយ៉ាងច្បាស់ ហើយបានយល់ព្រមស្ម័គ្រចិត្តផ្តិតមេដៃស្តាំលើកិច្ចព្រមព្រៀងនេះ ដោយគ្មានការបង្ខិតបង្ខំពីជនណាឡើយ។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង១៦និង០០នាទី នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយ៉ាងស្មោះត្រង់និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
រាជធានីភ្នំពេញ.ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

| | |
|---|---|
| **តំណាងភាគីសហជីពនិងតំណាងកម្មករនិយោជិត** | **តំណាងភាគីក្រុមហ៊ុន** |
| **ស្នាមមេដៃស្តាំ** | **ហត្ថលេខា និងត្រា** |